# វីងយីង(ខេមបូឌា)ហ្គាមេន ហ្វាក់ធើរី អិលធីឌី.

**អាសយដ្ឋានៈ** ផ្លូវជាតិលេខ 4, ភូមិ សាំងដំរី, ឃុំ ឆក់ឈើនាង, ស្រុកអង្គស្នួល, ខេត្តកណ្ដាល,ព្រះរាជាណាចក្រកម្ពុជា

## កិច្ចព្រមព្រៀង ស្ដីពីការព្យួរកិច្ចសន្យាការងារ

**កម្មករនិយោជិតចំនួន ៤៦ ចាប់ពី ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៣**

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំធ្វើរវាងរោងចក្រ វីងយីង(ខេមបូឌា)ហ្គាមេន ហ្វាក់ធើរី អិលធីឌី.
ដែលមានលោក CHENG KAI WING ជានាយកនិងជាតំណាងរោងចក្រ ហៅកាត់ថាភាគី (ក)
តំណាងកម្មករនិយោជិត នៃក្រុមហ៊ុន វីងយីង(ខេមបូឌា)ហ្គាមេន ហ្វាក់ធើរី អិលធីឌី. ហៅកាត់ថាភាគី (ខ)

**ភាគីទាំងពីរបានព្រមព្រៀងនិង គ្នាតាមប្រការ និងលក្ខខណ្ឌដូចខាងក្រោម៖**

**ប្រការ ១**

ភាគី (ក) នឹងរៀបចំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៤៦នាក់ គ្រប់ផ្នែក ដោយមូលហេតុខ្វះវត្ថុធាតុដើមនិងគ្មានការបញ្ជាទិញបណ្ដាលអោយគ្មានការងារធ្វើគ្រប់គ្រាន់ចាប់ពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៣

**ប្រការ ២**

ក. ក្នុងកំឡុងព្យួរកិច្ចសន្យាការងារភាគី (ក) បានព្រមព្រៀងផ្ដល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន **១៥ ដុល្លា** នៃប្រាក់ឈ្នួលអប្បរមា ក្នុងរយៈពេលនៃការព្យួរ សម្រាប់ កម្មករនិយោជិតម្នាក់ៗ យោងតាមសេចក្ដីណែនាំលេខ ០២០/២៣ កប/ស.ណ.ន.ខ.ល នៃក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**ប្រការ ៣**

ភាគី (ក) ត្រូវបើកប្រាក់ព្យួរការងារនេះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ តាមរយៈគណនេយ្យ ធនាគា ឯកទេសវីងរបស់កម្មករនិយោជិតម្នាក់ៗ។

**ប្រការ ៤**

ភាគី (ខ) ត្រូវត្រឡប់ចូលធ្វើការវិញនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះកម្មករនិយោជិតណាដែលមិនបានត្រឡប់មកធ្វើការវិញតាមកាលកំណត់ត្រូវចាត់ទុកថាឈប់អត់ច្បាប់។

ថ្ងៃពុធ១១កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ពស២៥៦៧
កណ្ដាលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

**ភាគី(ក)តំណាងក្រុមហ៊ុន**

WING YING (CAMBODIA) GARMENT FACTORY LTD.

CHENG KAI WENG

**ភាគី(ខ)តំណាងកម្មករនិយោជិត**